ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សេចក្តីជូនដំណឹង

I. ការដកស្រង់ពីច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ជំពូកទី ៩ ស្តីពីរូបិយវត្ថុ (ប្រាក់រៀល)

**មាត្រា ៥១.~**

ធនាគារកណ្តាលអាចបដិសេធមិនប្តូរក្រដាសប្រាក់និងកាស បើសិនជារូបភាពវាលែងមានភាពច្បាស់លាស់ បាត់បង់រូបភាពដើមឬផ្លុះធ្លាយឬដែលបាត់បង់ទំហំ ៣០% (សាមសិបភាគរយ) ឬលើសពីនេះ ។ រូបិយវត្ថុទាំងនេះត្រូវដកចេញពីចរាចរ ហើយបំផ្លាញចោលដោយគ្មានសំណងចំពោះម្ចាស់ទេ លើកលែងតែករណីពិសេសដែលធនាគារកណ្តាលអាចយល់ព្រមសងមួយចំណែកឬទាំងអស់ ។

**មាត្រា ៥២.~**

ក្រដាសប្រាក់ក្លែងក្លាយដែលយកមកបង់ឬប្តូរត្រូវរឹបអូសដោយគ្មានសំណង ហើយត្រូវជូនព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៥៣.~**

ម្ចាស់ប្រាក់មិនអាចទាមទារពីធនាគារកណ្តាលឱ្យសង ចំពោះក្រដាសប្រាក់ឬកាសណាដែលខ្លួនធ្វើឱ្យបាត់បង់ឬធ្វើឱ្យអន្តរាយឡើយ ។ ធនាគារកណ្តាលអាចដកហូតយកដោយគ្មានថ្នូរនូវក្រដាសប្រាក់ដែលមានការខូចខាតរូបភាពក្រៅ ជាពិសេសចំពោះក្រដាសប្រាក់ណាដែលមានសរសេរ លាបពណ៌ បោះពុម្ពបោះត្រាឬបិទវត្ថុស្អិតពីលើឬផ្លុះធ្លាយឬបាត់រូបភាពដោយប្រការណាក៏ដោយ ។

សូមបញ្ជាក់ថាៈ ក្រដាសប្រាក់គឺជាទម្រង់មួយនៃទ្រព្យសម្បត្តិ ហើយបុគ្គលដែលកាន់មានកាតព្វកិច្ចក្នុងការថែរក្សាឱ្យបានល្អ ដើម្បីប្រើប្រាស់ក្នុងប្រតិបត្តិការ ។ ការខូចខាតទ្រង់ទ្រាយ ឬការបាត់លក្ខណៈដើមនៃក្រដាសអាចធ្វើឱ្យក្រដាសប្រាក់នេះ បាត់តម្លៃឬត្រូវដកហូតចេញពីចរាចរ ។

II. ចំពោះករណីក្រដាសប្រាក់ដុល្លារអាមេរិក

ធនាគារជាតិនៃកម្ពុជាសូមជម្រាបជូនសាធារណជនជ្រាបថា ធនាគារជាតិនៃកម្ពុជានៅតែទទួលក្រដាសប្រាក់ដុល្លារអាមេរិកពីអតិថិជនរបស់ខ្លួន (គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ) ដែលមានគណនីនៅធនាគារជាតិនៃកម្ពុជា នៅពេលដែលក្រដាសប្រាក់ដុល្លារអាមេរិកនោះជាក្រដាសប្រាក់ពិតប្រាកដ មិនមែនក្លែងក្លាយ ហើយមានគុណភាពសមស្រប ។

III. ធនាគារជាតិនៃកម្ពុជាមិនមានកាតព្វកិច្ចទទួលក្រដាសប្រាក់រូបិយប័ណ្ណបរទេសចាស់ ទក់ រហែក មានស្នាមប្រឡាក់ ឆេះពោលដោយប្រការណាមួយ ហើយប្តូរយកក្រដាសប្រាក់ថ្មីបានឡើយ ។